002/19-09-2007-ECCC/TC
**E1/245**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 12 / 2014
ម៉ោង (Time/Heure) : 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ព្រហស្បតិ៍ ទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**សវនាការលើអង្គសេចក្តី - ថ្ងៃទី ២២៦**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Robynne CROFT**

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សាខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Robynne CROFT, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Nicholas KOUMJIAN, លោក ស្រ៊ា រតនៈ, លោក Dale LYSAK, លោក Joseph ANDREW BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា, លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ អវត្តមាន |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជអង្គ, លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក ហុង គឹមសួន, លោក វ៉ែន ពៅ, លោកស្រី ស៊ីន សុវ៉ន, លោក Yiqiang LIU |

| |
|---|
| សាក្សី/ដើមបណ្ដឹង៖ គ្មាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុធារី |
| ផ្សេងៗ៖ លោក Russell HOPKINS, លោក Sheriffo JAMMEH, កញ្ញា ស្រី ណាក់ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ | ចាប់ផ្ដើមម៉ោង៖ ០៩.១៥ | បញ្ចប់ម៉ោង៖ ១៣.៥៧ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ០៩.៣៦ | បញ្ចប់ម៉ោង៖ ១៣.៤១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៣៧ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៩.១៥ | ០៩.១៩ |
| ការប្រកាសអំពីអវត្តមានរបស់មេធាវីការពារក្ដី ខៀវ សំផន | អង្គជំនុំជម្រះ | ០៩.២០ | ០៩.២៦ |
| សំណើររបស់សហព្រះរាជអាជ្ញាអំពីមេធាវីមិត្តរបស់តុលាការ | សហព្រះរាជអាជ្ញា | ០៩.២៦ | ០៩.៣៤ |
| ការណែនាំដល់ជនជាប់ចោទ ខៀវ សំផន | អង្គជំនុំជម្រះ | ១៣.៤១ | ១៣.៥៤ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្ដី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធី។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែមេធាវីការពារក្ដីឱ្យលោក ខៀវ សំផន អវត្តមាន។

**ការប្រកាសអំពីអវត្តមានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន**

ប្រធានអង្គជំនុំជម្រះបង្គាប់ឱ្យ ខៀវ សំផន ឡើងជូនដំណឹងដល់អង្គជំនុំជម្រះ អំពីថាតើមេធាវីរបស់គាត់នៅទីណា។ ខៀវ សំផន បានបញ្ជាក់ថាគាត់បានណែនាំឱ្យមេធាវីរបស់ខ្លួនមិនចូលរួមក្នុងកិច្ច

ដំណើរការនីតិវិធីសវនាការ និងជូនដំណឹងដល់អង្គជំនុំជម្រះថា មេធាវីការពារក្ដីអន្តរជាតិរបស់គាត់នៅទីក្រុងប៉ារីស។

**<u>សំណើរបស់សហព្រះរាជអាជ្ញាអំពី មេធាវីមិត្តរបស់តុលាការ</u>**

សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ពីសំណើរបស់ខ្លួនដែលស្នើឱ្យ មានការចាត់តាំងមេធាវីមិត្តរបស់តុលាការ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គាំទ្រសំណើររបស់សហ ព្រះរាជអាជ្ញា។

**<u>ការណែនាំដល់ជនជាប់ចោទ ខៀវ សំផន</u>**

អង្គជំនុំជម្រះ ណែនាំដល់ជនជាប់ចោទ ខៀវ សំផន ថាប្រសិនបើគាត់ណែនាំឱ្យមេធាវីការពារក្ដីរបស់គាត់មិនចូលរួមក្នុងសវនាការលើអង្គសេចក្ដី ឬ កិច្ចដំណើរការនីតិវិធីផ្សេងទៀតសម្រាប់សំណុំរឿង ០០២/០២ អង្គជំនុំជម្រះអាចនឹងចាត់តាំងមេធាវីដោយមិនចាំបាច់មានការយល់ព្រមពីជនជាប់ចោទឡើយ ឬ នឹងចាត់វិធានការដែលសមស្របផ្សេង ដើម្បីធានានូវផលប្រយោជន៍យុត្តិធម៌ក្នុងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។ ជនជាប់ចោទ ខៀវ សំផន ធ្វើការឆ្លើយតប។

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- បង្គាប់ឱ្យជនជាប់ចោទ ខៀវ សំផន ជូនដំណឹងដល់អង្គជំនុំជម្រះតាមរយៈអង្គភាពគាំពារការការពារក្ដី យ៉ាងយូរត្រឹមម៉ោង ៤.៣០ រសៀល ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ថាតើគាត់នៅបន្ត ឬ មិនបន្តណែនាំដល់មេធាវីការពារក្ដីរបស់ខ្លួនមិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង ០០២/០២។
- អង្គជំនុំជម្រះបង្គាប់ឱ្យភាគីទាំងអស់ចូលរួមសវនាការនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលជូនសាក្សីត្រឡប់ទៅកាន់ទីលំនៅដ្ឋានវិញ រហូតដល់មានការជូនដំណឹងជាថ្មីពីអង្គជំនុំជម្រះ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

| <u>**កាលវេលាសវនាការបន្ត**</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ចាប់ផ្តើមពីម៉ោង ៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីវហ[illegible]** **Robynne CROFT**